ក្រសួងអប់រំរដ្ឋ NSW

# What do I need to know if I want to appeal a suspension or expulsion?

Parent/carer information

# តើខ្ញុំចាំបាច់ត្រូវដឹងពីអ្វីខ្លះ ប្រសិនបើខ្ញុំចង់ធ្វើបណ្ដឹងតវ៉ាមិនយល់ស្របចំពោះការបញ្ឈប់បណ្ដោះអាសន្ន ឬការបណ្ដេញចេញ?

## ព័ត៌មានសម្រាប់ឪពុកម្ដាយ/អ្នកថែទាំ

### តើអ្វីជាបណ្ដឹងតវ៉ាមិនយល់ស្រប?

បណ្ដឹងតវ៉ាមិនយល់ស្របគឺនៅពេលណា អ្នកស្នើសុំឱ្យមានការពិនិត្យមើលម្ដងទៀតនូវការសម្រេចចិត្តមួយ។ ការនេះកើតឡើងដោយសារតែអ្នកមិនសប្បាយចិត្តចំពោះការសម្រេចចិត្តដែលបានធ្វើឡើង។

### តើខ្ញុំអាចប្ដឹងតវ៉ាមិនយល់ស្របចំពោះការបញ្ឈប់បណ្ដោះអាសន្ន ឬការបណ្ដេញចេញដោយរបៀបណា?

អ្នកអាចប្ដឹងតវ៉ាមិនយល់ស្របចំពោះការបញ្ឈប់បណ្ដោះអាសន្ន ឬការបណ្ដេញចេញ ប្រសិនបើអ្នកជឿជាក់ថា នាយកសាលាបានធ្វើការសម្រេចចិត្តមិនយុត្តិធម៌ ឬមិនបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីត្រឹមត្រូវ។ សិស្ស ឪពុកម្ដាយ និងអ្នកថែទាំអាចបំពេញទម្រង់បែបបទបណ្ដឹងតវ៉ាមិនយល់ស្របមួយ។

បណ្ដឹងតវ៉ាមិនយល់ស្របអាចដាក់បាននៅការិយាល័យអប់រំក្នុងតំបន់។ ការិយាល័យអប់រំក្នុងតំបន់អាចជួយអ្នកឱ្យយល់ដឹងអំពីដំណើរការនេះ។ ពួកគេក៏អាចជួយអ្នកសរសេរបណ្ដឹងតវ៉ាមិនយល់ស្របផងដែរ។ សាលារៀនរបស់កូនអ្នកអាចផ្ដល់ព័ត៌មានទំនាក់ទំនង សម្រាប់ការិយាល័យអប់រំក្នុងតំបន់របស់អ្នក។

ការសម្រេចចិត្តអំពីបណ្ដឹងតវ៉ាមិនយល់ស្រប នឹងបានធ្វើឡើងដោយនាយកអ្នកដឹកនាំផ្នែកអប់រំ ឬនាយកប្រតិបត្តិ ការអនុវត្តសាលា ហើយនឹងចំណាយពេលពី15 ទៅ20ថ្ងៃសិក្សាដើម្បីដំណើរការ។ អ្នកនឹងត្រូវបានគេទាក់ទង នៅពេលបណ្ដឹងតវ៉ាមិនយល់ស្របត្រូវបានដាក់ ហើយការសម្រេចចិត្តត្រូវបានធ្វើឡើង។ ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម អ្នកអាចទាក់ទងមកការិយាល័យអប់រំក្នុងតំបន់ជាកន្លែងដែលដាក់បណ្ដឹងតវ៉ាមិនយល់ស្រប។

#### លទ្ធផលពីបណ្ដឹងតវ៉ាមិនយល់ស្រប ចំពោះការបញ្ឈប់បណ្ដោះអាសន្ន

ប្រសិនបើបណ្ដឹងតវ៉ាមិនយល់ស្រប អំពីការបញ្ឈប់បណ្ដោះអាសន្នត្រូវបានគាំទ្រ ហើយអ្នកដែលធ្វើការសម្រេចចិត្តយល់ព្រមតាមសំណើរបស់អ្នក នាយកសាលានឹងទាក់ទងមកអ្នក ដើម្បីប្រាកដថាកូនរបស់អ្នកត្រឡប់ទៅសាលារៀនវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ការសម្រេចចិត្តលើបណ្ដឹងតវ៉ាមិនយល់ស្របនឹងត្រូវបានកត់សម្គាល់នៅលើកំណត់ត្រារបស់កូនអ្នក ហើយការបញ្ឈប់បណ្ដោះអាសន្ន នឹងត្រូវបានដកចេញពីកំណត់ត្រារបស់កូនអ្នក។

ប្រសិនបើបណ្ដឹងតវ៉ាមិនយល់ស្រប អំពីការបញ្ឈប់បណ្ដោះអាសន្នមិនត្រូវបានគាំទ្រ ហើយអ្នកដែលធ្វើការសម្រេចចិត្តមិនយល់ស្របនឹងសំណើរបស់អ្នក កូនរបស់អ្នកនឹងបន្តការបញ្ឈប់បណ្ដោះអាសន្ន រហូតដល់កាលបរិច្ឆេទដែលបានព្រមព្រៀង។

#### លទ្ធផលពីបណ្ដឹងតវ៉ាមិនយល់ស្របចំពោះការបណ្ដេញចេញ

ប្រសិនបើបណ្ដឹងតវ៉ាមិនយល់ស្របអំពីការបណ្ដេញចេញត្រូវបានគាំទ្រ ហើយអ្នកដែលធ្វើការសម្រេចចិត្តយល់ស្របនឹងសំណើរបស់អ្នក នាយកសាលានឹងចាំបាច់ត្រូវធ្វើការជាមួយអ្នក ដើម្បីដោះស្រាយកង្វល់សុវត្ថិភាពធ្ងន់ធ្ងរណាមួយ ហើយដាក់វិធានការគាំទ្រឱ្យដំណើរការ ដើម្បីឱ្យកូនរបស់អ្នកអាចត្រឡប់ទៅសាលារៀនវិញ។ ការសម្រេចចិត្តលើបណ្ដឹងតវ៉ាមិនយល់ស្រប នឹងត្រូវបានកត់សម្គាល់នៅលើកំណត់ត្រារបស់កូនអ្នក ហើយការបណ្ដេញចេញនឹងត្រូវបានដកចេញពីកំណត់ត្រារបស់កូនអ្នក។

ប្រសិនបើបណ្ដឹងតវ៉ាមិនយល់ស្របអំពីការបណ្ដេញចេញ មិនត្រូវបានគាំទ្រទេ ហើយអ្នកដែលធ្វើការសម្រេចចិត្តមិនយល់ព្រមនឹងសំណើរបស់អ្នក អាចមានជម្រើសជាច្រើនផ្សេងទៀតដែលមានសម្រាប់កូនរបស់អ្នក។ នាយកសាលានឹងធ្វើការជាមួយអ្នក ដើម្បីរៀបចំដាក់កូនរបស់អ្នកឱ្យរៀននៅសាលាមួយផ្សេងទៀតដែលសមស្របទៅនឹងតម្រូវការរបស់កូនអ្នក។

ប្រសិនបើបណ្ដឹងតវ៉ាមិនយល់ស្របអំពីការបណ្ដេញចេញ មិនត្រូវបានគាំទ្រទេ ហើយកូនរបស់អ្នកមានអាយុលើសពី17ឆ្នាំ អ្នក និងកូនរបស់អ្នកគួរតែរកមើលជម្រើសនានាដើម្បីបន្តការរៀនសូត្រ ឬការធ្វើអន្តរកាលទៅកាន់ការងារ។

### តើខ្ញុំអាចទទួលបានព័ត៌មានអ្វីខ្លះពីសាលារៀន?

អ្នកអាចសួររកព័ត៌មានបន្ថែមពីសាលារៀន អំពីអ្វីដែលបានកើតឡើង និងមូលហេតុ។ សាលារៀនគួរតែពន្យល់ដល់អ្នកអំពីហេតុផលនៅពីក្រោយការសម្រេចចិត្តណាមួយ សកម្មភាពនឹងកើតឡើង និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នកមានបញ្ហា។

### តើខ្ញុំធ្វើបណ្ដឹងតវ៉ាដោយរបៀបណា?

ព័ត៌មានអំពីការតស៊ូមតិសម្រាប់កូនរបស់អ្នកគឺអាចរកបានសម្រាប់ឪពុកម្ដាយ។ ព័ត៌មានអំពីការធ្វើបណ្ដឹងតវ៉ាក៏អាចរកបានផងដែរ ប្រសិនបើអ្នកនៅតែមានការព្រួយបារម្ភអំពីដំណើរការប្ដឹងតវ៉ាមិនយល់ស្របចំពោះការបញ្ឈប់បណ្ដោះអាសន្ន ឬការបណ្ដេញចេញ។

ព័ត៌មានស្ដីពីការប្រាស្រ័យទាក់ទងជាមួយសាលារៀន មានផ្ដល់ជូននៅក្នុងធម្មនុញ្ញសហគមន៍សាលារៀន។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ហើយត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទតាមលេខ 131 450 ប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការីទូរសព្ទទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទដើម្បីជួយអ្នកនៅក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។